**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានព័ត៌មាន**

សេចក្តីប្រកាសព័ត៌មាន

# "កម្ពុជា និងចិន ត្រៀមប្រារព្ធឆ្នាំនៃការផ្លាស់ប្តូរប្រជាជន និងប្រជាជន នៅឆ្នាំ២០២៤"

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួបពិភាក្សាការងារប្រកបដោយផ្លែផ្កាជាមួយ **ឯកឧត្តម Wang Wentian** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា ក្នុងឱកាស ឯកឧត្តម ឯកអគ្គរដ្ឋទូត ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួង។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកសម្រាប់ប្រទេស និងប្រជាជនទាំងពីរ ព្រមទាំងបានសម្តែងនូវសុទិដ្ឋិនិយមរួមគ្នាថា ភាពជាដៃគូជិតស្និទ្ធនេះនឹងកាន់តែរីកចម្រើនលូតលាស់បន្ថែមទៀត។ ភាគីទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តឥតងាករេក្នុងការអនុវត្តកិច្ចព្រមព្រៀង និងកុងសង់ស៊ីស ដែលថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរ បានឯកភាពជាមួយគ្នានាពេលកន្លងមក រួមមាន (១) ការដាក់ចេញនូវ "កិច្ចសហប្រតិបត្តិការត្បូងពេជ្រ" និង (២) ការបង្កើត "ច្រករបៀងឧស្សាហកម្មនិងបច្ចេកវិទ្យា" និង "ច្រករបៀងមច្ឆា និងអង្ករ" ដែល**សម្តេចតេជោ ហ៊ុន សែន** និង **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** បានឯកភាពគ្នា កាលពីខែកុម្ភៈ ឆ្នាំ២០២៣។

ភាគីទាំងពីរបានកត់សម្គាល់ដោយការពេញចិត្តនូវជំនួបប្រកបដោយផ្លែផ្ការវាង**សម្តេចធិបតី ហ៊ុន ម៉ាណែត** និងថ្នាក់ដឹកនាំចិន ជាពិសេសជំនួបជាមួយ **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** និង **ឯកឧត្តមនាយករដ្ឋមន្ត្រី លី ឈាង** ក្នុងឱកាសទស្សនកិច្ចរបស់ **សម្តេចធិបតី** ទៅកាន់ប្រទេសចិន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានឯកភាពផ្តួចផ្តើមឱ្យមានសកម្មភាពគ្រប់ជ្រុងជ្រោយ ដើម្បីត្រៀមប្រារព្ធ "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជន និងប្រជាជន" ដែលគ្រោងធ្វើនៅឆ្នាំ ២០២៤ សំដៅទាក់ទាញទេសចរចិនមកទស្សនាកម្ពុជាបន្ថែមទៀត។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ដែលបានបំពេញតួនាទីដ៏សំខាន់ក្នុងការសម្របសម្រួលដំណើរទស្សនកិច្ចកម្រិតខ្ពស់ និងកិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរ និងចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់ជំនួយនិងការគាំទ្រដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ព្រះរាជាណាចក្រកម្ពុជា។

បន្ថែមលើកិច្ចពិភាក្សាអំពីប្រធានបទទ្វេភាគី ភាគីទាំងពីរបានផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់និងអន្តរជាតិដែលជាប្រយោជន៍និងកង្វល់រួម ព្រមទាំងភាពជាដៃគូអាស៊ាន-ចិន និងសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវមជ្ឈភាពអាស៊ាន។

ថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣